01075882

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 03 / 2015
ម៉ោង (Time/Heure): 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
E1/271

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

### សាធារណៈ

### សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

### ថ្ងៃ ពុធ ទី ០៤ ខែ មីនា ឆ្នាំ ២០១៥

### សវនាការលើអង្គសេចក្ដី - ថ្ងៃ ២៥២

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង **Maddalena GHEZZI**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម ធូ មណី (ជំនួសចៅក្រម យូរ ឧត្តារ៉ាដែលអវត្តមាន) |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ាង, លោកស្រី Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, លោក Vincent de Wilde d'ESTMAEL, លោក Nicholas KOUMJIAN, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោកស្រី ស៊ីន សុរ៉ុន, លោក |

| |
|---|
| ហុង គឹមសួន, លោក ឡៅ ជុនធី, លោកស្រី ជេត វណ្ណលី |
| សាក្សី/ដើមបណ្តឹង ៖ លោក វ៉ាន់ សឿន (2-TCW-847), លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) |
| មន្រ្តីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធារី |
| ផ្សេងៗ៖ កញ្ញា សុក សុភ័គមណីកា, លោក នូ មនោរត្ន័, កញ្ញា ឈួក គឹមម៉ៅ, លោកស្រី ពេជ ចរិយា, លោក ហ៊ូ ជីសេង, លោក Mario D'ALESSANDRO |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០៨ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៣ | បញ្ចប់ម៉ោង៖ ១០.៣៤ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៤២ | បញ្ចប់ម៉ោង៖ ១៣.៣៤ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ៣០ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៦ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៦ | ០៩.១២ |
| ការតាំងសំណួរទៅសាក្សី វ៉ាន់ សឿន (2-TCW-847) | សហព្រះរាជអាជ្ញា<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា | ០៩.១២<br>១១.០៣<br>១១.២៨<br>១៣.៣៩ | ១១.០២<br>១១.២៨<br>១១.៤២<br>១៥.៤០ |
| ការលើកអំពីកិច្ចពិភាក្សាទាក់ទងនឹងសំណើសុំផ្អាកសវនាការ | អង្គជំនុំជម្រះ | ១៣.៣៦ | ១៣.៣៩ |
| ការពិភាក្សាទាក់ទងនឹងការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង០០៤ និង | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ១៥.៤១<br>១៥.៥០ | ១៦.០៦<br>១៥.៥៧ |

| | | | |
|---|---|---|---|
| សំណើរបស់មេធាវីការពារក្តី នួន ជា សុំផ្អាក សវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-803 | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ១៥.៥៨<br>១៦.០៣<br><br>១៦.០៥ | ១៦.០៣<br>១៦.០៥<br><br>១៦.០៨ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីបានរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែជនជាប់ចោទ នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ ដោយឡែក លោក Arthur VERCKEN ដែលជាមេធាវីអន្តរជាតិការពារក្តី លោក ខៀវ សំផន អវត្តមានដោយសារបញ្ហាសុខភាព។

**សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ក្នុងការលះបង់សិទ្ធចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ និងតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួន ស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅសាក្សី វ៉ាន់ សឿន (2-TCW-847)**

សហព្រះរាជអាជ្ញាបានចាប់ផ្តើមតាំងសំណួរទៅសាក្សី បន្ទាប់មក មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ និងមេធាវីការពារក្តី នួន ជា បានតាំងសំណួរបន្តទៅសាក្សី។

**ការពិភាក្សាទាក់ទងនឹងការដាក់បង្ហាញឯកសារថ្មីៗពីសំណុំរឿង០០៣ និង០០៤ និងសំណើសុំរបស់មេធាវីការពារក្តី នួន ជា សុំផ្អាកកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-803**

មេធាវីការពារក្តី នួន ជា បានធ្វើសំណើដោយផ្ទាល់មាត់ទាក់ទងនឹងការសុំផ្អាកកិច្ចដំណើរការសវនាការ និងពន្យារពេលស្តាប់សក្ខីកម្មសាក្សី 2-TCW-803 និង 2-TCW-809។ សហព្រះរាជអាជ្ញាបានធ្វើការជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានជំទាស់ទៅនឹងការស្តាប់សក្ខីកម្មរបស់សាក្សី 2-TCW-803 តាមកាលវិភាគដែលបានគ្រោងទុកនោះទេ។ អង្គជំនុំជម្រះបញ្ជាក់ថា អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើបញ្ហានេះក្នុងពេលឆាប់ៗ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃកិច្ចតាង**

## New E3s

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5858 | D232/73.2 | 00068049-00068049 00809682-00809682 00858031-00858031 | Annex2: Educational Office 105 | P | 00068049 | 00809682 | 00858031 |

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4099 | | 00270976-00270977 00322122-00322123 00858037-00858038 | Report to Angkar on the sending of four people | P | 00270976 | 00322122 | 00858037 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E319.1.33 | | 00968170-00968196 00980277-00980305 00982607-00982632 | Written Record of Interview of [REDACTED] | SC | 00968175 00968176 00968177 00968178 00968179 00968180 00968181 00968182 00968186 00968187 00968189 00968190 00968192 00968194 00968195 00968196 | 00980282 00980285 00980286 00980287 00980289 00980293 00980294 00980295 00980297 00980298 00980299 00980301 00980302 00980303 00980304 | 00982611 00982612 00982614 00982615 00982616 00982617 00982618 00982621 00982622 00982624 00982625 00982626 00982628 00982629 00982630 00982630 |
| E3/5845 | | 00165351-00165358 00223207-00223213 00490905-00490913 | Written Record of Interview of VAN Soeun | P | 00165352 00165353 00165354 00165355 00165356 00165357 00165358 | 00223209 00223210 00223211 00223213 | 00490907 00490909 00490910 00490911 00490912 00490913 |
| E3/5853 | | 00165328-00165336 00433567-00433575 00524316-00524324 | Written Record of Interview of SAING Sim | P | 00165332 00165333 00165334 | 00433571 00433573 00433574 | 00524320 00524321 00524322 |
| E3/2109 | | 00068014-00068016 00276555-00276556 00290272-00290274 | Report on prisoners by late November 1977 | P | 00068014 | 00276555 | 00290272 |
| E3/4093 | | 00270786-00270793 00831486-00831492 00729674-00729677 | Report on smashing of four widows in Takeo | P | 00270786 00270787 | 00831486 | 00729674 |
| E3/5834 | | 00427971-00427981 00434687-00434697 00434698-00434708 | Written Record of Interview of SREI Thân | C | 00427978 | 00434694 | 00434705 |

| **ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖** |
|---|
| • អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តតាមដានសវនាការនៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ <br>• បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ។ |

| **កាលវេលាសវនាការបន្ត** |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ កុលឧត្តម Maddalena GHEZZI